**មជ្ឈមណ្ឌលព្រះពុទ្ធសាសនាអប់រំយុវជន(មពអយ)**
**Youth Education Buddhist Center(YEBC)**
វត្តប្រាសាទបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា
**Tel:** +៨៥៥-១២-៣១ ២៩ ០៨,១២-៣២៩ ៦៩៤, ១២-៩១៣ ៧២៤, ១៧ ៣៧៩ ៧៣០
**E-mail: kyso2005@yahoo.com /www.cambodianyouth.org**

# គម្រោងធម្មចារិក

**អប់រំសីលធម៌ សុជីវធម៌ខ្មែរ តាមពុទ្ធឱវាទដល់ក្រុមយុវវ័យ ដើម្បីអូសទាញឱ្យក្លាយជាសមាជិកដ៏ល្អរបស់សង្គមជាតិខ្មែរ កែខ្លួនឱ្យឆ្ងាយពីអបាយមុខ ក្រុមបងធំបងតូច និងគ្រឿងញៀនគ្រប់ប្រភេទ ។**

**រៀបចំកម្មវិធីដោយ**: មជ្ឈមណ្ឌលព្រះពុទ្ធសាសនាអប់រំយុវជន សមណនិស្សិតខ្មែរ រួមសហការជាមួយ លោកនាយក នាយករង **វិទ្យាល័យទេពប្រណម្យ** ។

**អប់រំចាប់ផ្តើមពីថ្ងៃទី០១ ខែមិថុនា ដល់ថ្ងៃទី០៥ ខែមិថុនា ព.ស.២៥៥៥ គ.ស.២០១១**

## ១. ឈ្មោះគម្រោងកម្មវិធី

គម្រោងធម្មចារិក "**អប់រំសីលធម៌ សុជីវធម៌ដល់សិស្សានុសិស្ស យុវជនខ្មែរ**"

## ២. គោលការណ៍ និងហេតុផល

ដោយពុទ្ធសាសនាក្នុងព្រះរាជាណាចក្រកម្ពុជាជាសាសនារបស់រដ្ឋ ហើយកំពុងតែរីកចម្រើនជាបណ្តើរៗក្នុងពេលបច្ចុប្បន្នក្រោយពីសង្គ្រាមក្នុងស្រុកត្រូវបានស្ងប់រំងាប់ៗទន្ទឹមនឹងការរីកចម្រើនលូតលាស់នេះ ព្រះពុទ្ធសាសនាកំពុងប្រឈមមុខបញ្ហាច្រើនយ៉ាង ដូចជា ខ្វះខាតបណ្ឌិតអ្នកប្រាជ្ញ ខ្វះខាតគម្ពីរក្បួនខ្នាតផ្សេងៗ ដែលជាប្រភពធនធានមនុស្សដ៏សំខាន់ក្នុងការអភិវឌ្ឍសង្គមជាតិ ជាពិសេស ក្រុមយុវជន ដែលជាជន្ទល់ដ៏រឹងមាំ ជាសសរទ្រូងបេះដូងជាតិ និងសាសនា បានកំពុងសប្បាយភ្លើតភ្លើននឹងវត្ថុនិយម ឃ្លាតឆ្ងាយពីវត្តអារាម ខ្វះសីលធម៌ ខ្វះទំនួលខុសត្រូវនូវតួនាទីរបស់ខ្លួនឯង ដោយឥទ្ធិពលវប្បធម៌ អរិយធម៌បរទេស និងការឈឺចុកផ្សាន្ធវមុខរបួសខាងផ្លូវសតិអារម្មណ៍ពីអតីតកាល គ្របសង្កត់ចិត្តគំនិតធ្វើឱ្យមានបញ្ហាសង្គមកើតឡើងមិនអាចគេចវេសបាន។

ដោយមើលឃើញបញ្ហាទាំងអស់នេះ ទើបបង្កើតគម្រោងការនេះឡើង ដើម្បីផ្តល់ឱកាសឱ្យក្មេង យុវជន សិស្សនិស្សិត កុមារា កុមារី ដែលជាកុលបុត្រកុលធីតាខ្មែរ បានចូលមកសិក្សា និងបដិបត្តិតាមគន្លងមាគ៌ាព្រះពុទ្ធសាសនាឱ្យស្គាល់ពីតម្លៃព្រះពុទ្ធសាសនា ដែលជាមត៌កធម៌ដ៏សំខាន់របស់ជាតិខ្មែរ និងដើម្បីឱ្យយុវជនទាំងអស់នេះ ក្លាយទៅជាបុគ្គលល្អ មានសីលធម៌ មានវិន័យ និងមានការទទួលខុសត្រូវនូវតួនាទីរបស់ខ្លួនឯង ដែលត្រូវជាទំពាំងស្នងឫស្សីនៃទឹកដីជាតិមាតុភូមិខ្មែរ សក្តិសមជាវីរបុរស មហាវីរបុរស មហារដ្ឋបុរស ដឹកនាំសង្គមប្រទេសជាតិខ្មែរឈានទៅរកភាពរីកចម្រើន ដូចអារ្យប្រទេសនានាក្នុងពិភពលោក និងមានសុខសន្តិភាព ថ្កុំថ្កើងរុងរឿងដូចសម័យកាលមហានគរនៃយើង។

**៣. វត្ថុបំណង**

-ដើម្បីឱ្យយុវជនខ្មែរមានឱកាសចូលមកសិក្សា និងបដិបត្តិព្រះធម៌ក្នុងព្រះពុទ្ធសាសនា។

-ដើម្បីហ្វឹកអប់រំយុវជនខ្មែរឱ្យស្គាល់នូវតម្លៃសិល្បៈ ទំនៀមទម្លាប់ ប្រពៃណី វប្បធម៌ជាតិរបស់ខ្លួន។

-ដើម្បីហ្វឹកអប់រំយុវជនខ្មែរឱ្យមានសីលធម៌ សុជីវធម៌ មានចរិយាមារយាទល្អប្រពៃ មានវិន័យថ្លៃថ្នូរ មានវិជ្ជាដើរតួទន្ទឹមគ្នានឹងគុណធម៌ ។

-ដើម្បីហ្វឹកអប់រំយុវជនខ្មែរឱ្យក្លាយទៅជាកូនដ៏ល្អរបស់ឪពុកម្តាយ ជាសិស្សដ៏ល្អរបស់គ្រូ ជាមិត្តដ៏ល្អរបស់មិត្ត ជាពលរដ្ឋ ដ៏ល្អរបស់សង្គមជាតិ និងជាពុទ្ធសាសនិកជនដ៏ល្អរបស់ព្រះពុទ្ធសាសនា។

-ដើម្បីហ្វឹកអប់រំយុវជនខ្មែរឱ្យមានស្មារតីភ្ញាក់រឭក ស្រលាញ់នូវស្ថាប័នជាតិ សាសនា និងព្រះមហាក្សត្រ ធ្វើខ្លួនឱ្យឆ្ងាយពីអបាយមុខ គ្រឿងញៀនគ្រប់ប្រភេទ ឈប់បង្កើតបងធំបងតូចវាយតប់កាប់សម្លាប់គ្នា ធ្វើខ្លួនឱ្យសក្តិសមជាទំពាំងស្នងឫស្សីរបស់ជាតិ។

-ដើម្បីឱ្យយុវជនខ្មែរបានសិក្សាគោលធម៌៥ សីល៥ និងបដិបត្តិសមាធិចម្រើនភាវនាអប់រំចិត្ត ឱ្យស្ងប់សុខ បរិសុទ្ធស្អាតស្អំ ភ្ញាក់ខ្លួន រឭកដឹងគុណគោរពមាតាបិតា គ្រូ ព្រឹទ្ធាចារ្យ និងជាកាតព្វកិច្ចតបថ្វាយ **សម្តេចឪ សម្តេចម៉ែ ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះរាជវង្សានុវង្សគ្រប់ព្រះអង្គ ជាពិសេស សូមឱ្យប្រជាជនខ្មែរទាំងអស់មានសុខភាពល្អ រំដោះខ្លួនចេញផុតពីភាពអត់ឃ្លាន ក្រីក្រ និង សូមឱ្យព្រះរាជាណាចក្រកម្ពុជាយើងទទួលនូវសុខសន្តិភាពយ៉ាងពិតប្រាកដជាដរាបតរៀងទៅ។

-ដើម្បីយុវជនបានរួមចំណែកទទួលខុសត្រូវចំពោះជាតិខ្មែរ អភិវឌ្ឍន៍ជាតិខ្មែរជាមួយរាជរដ្ឋាភិបាល ធ្វើខ្លួនឱ្យក្លាយជាមហាវីរបុរស ដូចបុព្វព្រះមហាវីរក្សត្រខ្មែរ បុព្វមហាវីរបុរសខ្មែរ មហារដ្ឋបុរសខ្មែរ ដូចមាន សម្តេចព្រះសង្ឃរាជ **ជួន ណាត** និង**សម្តេចព្រះបាទជ័យវរ្ម័នទី៧** ជាដើម និងអ្នកប្រាជ្ញ បញ្ញវន្ត កវី បណ្ឌិត អ្នកស្នេហាជាតិ ដែលបានបូជាព្រះជន្ម ពលីជីវិត ដើម្បីការពារសាសនា វប្បធម៌ និងជាតិមាតុភូមិខ្មែរឱ្យរីកចម្រើនរុងរឿង បិតស្នេរគង់វង្សដល់សព្វថ្ងៃ។

**៤. ក្រុមគោលដៅ**

យុវសិស្ស **វិទ្យាល័យទេពប្រណម្យ** ដែលមានចាប់ពីថ្នាក់ទី៧ដល់ថ្នាក់ទី១២ ចំនួនសិស្សានុសិស្សទាំងអស់ មាន ១,៩៩៣នាក់, សិស្សស្រីចំនួន ៩៤៣ នាក់ សិស្សប្រុសចំនួន ១,០៥០នាក់ និងគ្រូចំនួន ៨០ នាក់ ។

**៥. ទីកន្លែងធ្វើការអប់រំ**

សាលារៀន **វិទ្យាល័យទេពប្រណម្យ** ភូមិទេពប្រណម្យ ឃុំវិហារហ្លួង ស្រុកពញាឮ ខេត្តកណ្តាល។

**៦. រយៈពេលក្នុងការអប់រំ**

ចាប់ផ្តើមពីថ្ងៃទី០១ ខែមិថុនា ដល់ថ្ងៃទី០៥ ខែមិថុនា ព.ស.២៥៥៥ គ.ស.២០១១ រួមទាំងអស់ប្រើរយៈពេល០៥ថ្ងៃ។

**៧. ស្ថាប័នចូលរួមសហការ និងអ្នកមានចំណែកចូលរួមឧបត្ថម្ភគាំទ្រ**

១-មជ្ឈមណ្ឌលព្រះពុទ្ធសាសនាអប់រំយុវជន

២-នាយកវិទ្យាល័យទេពប្រណម្យ

៣-អាជ្ញាធរមូលដ្ឋាន និងក្រុមសមត្ថកិច្ចដែលពាក់ពន្ធ័

៤-ក្រុមសមណនិស្សិត សិស្សគណព្រះតេជព្រះគុណ **ព្រះគ្រូ អ៊ួន ប៉ក់**

៥-សប្បុរសជន ពុទ្ធបរិស័ទទូទៅ ទាំងក្នុង និងក្រៅប្រទេស

**៨. អ្នកទំនាក់ទំនង និងដំណើរការរៀបចំកម្មវិធីអប់រំ**

-សមណនិស្សិត បុគ្គលិកនៃមជ្ឈមណ្ឌលព្រះពុទ្ធសាសនាអប់រំយុវជន

**៩. វិធីដំណើរការកម្មវិធីអប់រំ**

-ធ្វើលិខិតសុំអនុញ្ញាតពីក្រសួងសមត្ថកិច្ចដែលពាក់ពន្ធ័តាមរយៈអាជ្ញាធរមូលដ្ឋាន

-ប្រកាសឃោសនាតាមទូរទស្សន៍ វិទ្យុ កាសែត អ៊ិនធ័រណិត និង ផ្តល់ពត៌មានដល់សាលារៀន អង្គការ ស្ថាប័ន សមាគម មូលនិធិ និងពុទ្ធបរិស័ទទាំងក្នុង និងក្រៅប្រទេស។

**១០. កម្មវិធីអប់រំ និងវិធីការបង្រៀន**

***១០.១. ផ្នែកជំនាញការ ឬពិធីការ***

-វិជ្ជា ប្រវត្តិព្រះពុទ្ធសាសនា ពុទ្ធប្បវត្តិ

-វិជ្ជាធម្ម និងជីវិតយុវវ័យសម័យថ្មី មានត្រៃសិក្ខា គោលធម៌នៃសេចក្តីសម្រេច ភាវៈជាអ្នកដឹកនាំ ជាដើម

-វិជ្ជាសីលធម៌ និង ចរិយាធម៌ (សីល ៥, ធម៌ ៥) និង គោលធម៌យុវជនផ្ទើមប្រាំយ៉ាង

-វិជ្ជា វប្បធម៌ ប្រពៃណីខ្មែរ និងសាសនពិធី ពិធីបុណ្យផ្សេងៗ

-វិជ្ជា អំពីព្រះរតនត្រ័យ និងការអភិវឌ្ឍជីវិតតាមទ្រឹស្តីថ្ងៃប្រសូត្រ ត្រាស់ដឹង បរិនិព្វាន

-វិជ្ជា ព្រះពុទ្ធសាសនា ជាភាសាអង់គ្លេស

***១០.២. ផ្នែកបដិបត្តិ ឬអនុវត្តន៍ផ្ទាល់***

-នមស្សការព្រះរតនត្រ័យ សមាទានសីល (៥)

-ហ្វឹកធ្វើសមាធិ ចម្រើនភាវនា ដើរចង្ក្រម ផ្សាយមេត្តាធម៌

-ហ្វឹកហាត់ចរិយាមារយាទខ្មែរ គារវកិច្ច ការនិយាយស្តី និង របៀបក្រាបសំពះ ថ្វាយបង្គំ ជាដើម

-ល្បែងបញ្ញា ធម្មរីករាយសប្បាយអារម្មណ៍បង្កប់ខ្លឹមសារ សម្តែងសេចក្តីក្លាហាន ចោទឆ្លើយសំណួរផ្សេងៗ

***១០.៣. ផ្នែកសកម្មភាពក្នុងសង្គម***

-ហ្វឹកហាត់ការថ្លែងការណ៍ សង្កថា សុន្ទរកថា អធិប្បាយវែកញែក និង វេទិកាអធិប្បាយជាក្រុម

-ហ្វឹកហាត់ឱ្យចេះបង្កើតគំនិត និងបញ្ញាច្នៃប្រឌិតទស្សនៈថ្មីៗ និងចេះដោះស្រាយជំលោះផ្សេងៗ

-ផ្លាស់ប្តូរយោបល់រវាងអ្នកចូលមកអប់រំ និងគណៈគ្រូធម្មាចារ្យអ្នកផ្តល់ការអប់រំ

-ហ្វឹកហាត់បណ្តុះគំនិតស្រឡាញ់ជាតិ មានទំនួលខុសត្រូវចំពោះស្ថាប័នជាតិ សាសនា និងព្រះមហាក្សត្រ

-ហ្វឹកហាត់ឱ្យចេះស្រឡាញ់នូវវប្បធម៌ អរិយធម៌ ប្រពៃណី រហូតដល់សង្គមបរិស្ថាន ធម្មជាតិនៅជុំវិញខ្លួន

***១០.៤. ផ្នែកអត្ថាធិប្បាយពិសេស***

-នាទីធម្មសង្វេគ "***អត្ថាធិប្បាយពិសេស ស្តីពីគុណទឹកដោះម្តាយ»***

**១១. វាគ្មិនពិសេស និងគ្រូធម្មាចារ្យផ្តល់ការអប់រំដល់អ្នកចូលមកអប់រំ**

***១. វាគ្មិនពិសេសដែលមកផ្តល់ចំណេះដឹង***

-ព្រះរាជាគណៈ ព្រះមេគណ ព្រះអនុគណ និងព្រះសង្ឃដែលមានការសិក្សា និងបទពិសោធន៍ខ្ពស់

-អភិបាលខេត្ត អភិបាលស្រុក ប្រធានមន្ទីរធម្មការ និងសាសនាខេត្ត-ស្រុក និងអ្នកមានវាទសិល្បៈល្បីៗ

-អ្នកមុខ អ្នកការ ភ្ញៀវកិត្តិយសទូទៅ អង្គការ និងសមាគមផ្សេងៗ ជាដើម

២. គ្រូធម្មាចារ្យ ផ្តល់ការអប់រំប្រចាំគម្រោង

សមណសិស្ស និស្សិត ព្រះសង្ឃ ដូនជី ដែលមានការសិក្សា ចំណេះដឹង និងបទពិសោធន៍ច្រើនឆ្នាំ

## ១២. គណៈកម្មការឧបត្ថម្ភគាំទ្រ និងគ្រូធម្មាចារ្យ រៀបចំគម្រោងកម្មវិធីអប់រំ

| | | |
|---|---|---|
| ១-លោក **បូ ពៅ** | គណៈកម្មការឧបត្ថម្ភ | រស់នៅរាជធានីភ្នំពេញ |
| ២-លោក **ហូ តិមឡុង** | គណៈកម្មការឧបត្ថម្ភ | រស់នៅប្រទេសជប៉ុន |
| ៣-លោក **សេង សុភ័ណ** | គណៈកម្មការឧបត្ថម្ភ | រស់នៅប្រទេសកាណាដា |
| ៤-ភិក្ខុ **វ៉ាត់ វិបុល** | ប្រធានគម្រោងកម្មវិធី | បរិញ្ញាប័ត្រទស្សនវិជ្ជា |
| ៥-ភិក្ខុ មហា **ហ៊ឹ សុទ្ធា** | ប្រធានផ្នែកអប់រំ | សមណនិស្សិតពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ |
| ៦-ភិក្ខុ **ស៊ឹម ផាន់ណា** | អនុប្រធានផ្នែកអប់រំ | អនុបណ្ឌិតសាកលវិទ្យាល័យបៀលប្រាយ |
| ៧-ភិក្ខុ មហា **ដោក ជុំ** | ហិរញ្ញិក | សមណនិស្សិតសាកលវិទ្យាល័យជាតិគ្រប់គ្រង |
| ៨-ភិក្ខុ មហា **ម៉ៅ ខា** | លេខាធិការ | សមណនិស្សិតសាកលវិទ្យាល័យឯកទេសកម្ពុជា |
| ៩-ភិក្ខុ មហា **កង សុវណ្ណមុនី** | ជំនួយការគម្រោង | សមណនិស្សិតសាកលវិទ្យាល័យកម្ពុជា |
| ១០-ភិក្ខុ មហា **សុខ សារេតា** | ជំនួយការហិរញ្ញិក | សមណនិស្សិតសាកលវិទ្យាល័យបៀលប្រាយ |
| ១១-ភិក្ខុ មហា **ហែម សុធា** | ឧទ្ទេសាចារ្យ | សមណនិស្សិតសាកលវិទ្យាល័យអង្គរ |
| ១២-ភិក្ខុ មហា **សាយ ភិរុណ** | ឧទ្ទេសាចារ្យ | សមណនិស្សិតសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា |
| ១៣-ភិក្ខុ មហា **ជឿម សាម៉ន** | ការីកំព្យូទ័រនិងវិដេអូ | សមណនិស្សិតសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា |

## ១៣. ថវិកា ឬបច្ច័យដែលនឹងត្រូវចំណាយប្រើប្រាស់លើកម្មវិធីអប់រំ

| | | |
|---|---|---|
| -ចំណាយទៅលើ ឯកសារ សម្រាប់បង្រៀន | ចំនួន | ៤០០.០០០៛ |
| -ចំណាយទៅលើថ្លៃចង្ហាន់ព្រឹក-ថ្ងៃត្រង់ រយៈពេល០៥ថ្ងៃ | ចំនួន | ៨០០.០០០៛ |
| -ចំណាយទៅលើទឹកសុទ្ធ ទឹកភេសជ្ជៈ រយៈពេល០៥ថ្ងៃ | ចំនួន | ៦០០.០០០៛ |
| -ចំណាយទៅលើយានជំនិះសម្រាប់ធម្មាចារ្យចំនួន១០អង្គ/នាក់ | ចំនួន | ១.០០០.០០០ ៛ |
| -ចំណាយផ្សេងៗ | ចំនួន | ៤០០.០០០ ៛ |

## ១៤. ប្រភពចំណូលនៃថវិកា (បច្ច័យ)

-សម្តេច ទ្រង់ អ្នកអង្គម្ចាស់ ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ និងញាតិញោម ពុទ្ធបរិស័ទ សប្បុរសជនទូទៅ ទាំងក្នុង និងក្រៅប្រទេស។

-អង្គការ ស្ថាប័ន មូលនិធិ និងក្រុមហ៊ុនផ្សេងៗ ក្នុង និងក្រៅប្រទេស

## ១៥. លទ្ធផលដែលនឹងអាចទទួលបានក្រោយពីការអប់រំ

-ធ្វើឱ្យយុវជនខ្មែរយល់នូវគោលធម៌ព្រះពុទ្ធសាសនា ហើយអាចយកទៅបដិបត្តិពិតក្នុងជីវិតប្រចាំថ្ងៃបាន។

-ធ្វើឱ្យយុវជនខ្មែរមានការភ្ញាក់រឭក ចេះស្រឡាញ់ស្ថាប័នជាតិ សាសនា និងព្រះមហាក្សត្រកាន់តែខ្លាំង។

-ធ្វើឱ្យយុវជនខ្មែរមានការផ្លាស់ប្តូរអាកប្បកិរិយា ការប្រព្រឹត្ត តាមផ្លូវល្អត្រឹមត្រូវ យកចិត្តទុកដាក់ក្នុងការសិក្សារៀនសូត្រ អភិវឌ្ឍន៍ខ្លួនឯងកាន់តែល្អប្រសើរឡើង មានសីលធម៌ វិន័យថ្លៃថ្នូរ ចេះគោរពច្បាប់ទម្លាប់។

-ធ្វើឱ្យយុវជនស្គាល់តម្លៃនៃជីវិត ចេះស្រឡាញ់ជីវិតខ្លួន ជីវិតអ្នកដទៃ ចេះស្រឡាញ់បរិស្ថានសង្គម បរិស្ថានធម្មជាតិ វប្បធម៌ អរិយធម៌ ទំនៀមទម្លាប់ ប្រពៃណីខ្មែរយើង រួមគ្នាថែរក្សាបានគង់វង្សតរៀងទៅ ។

-ប្រព្រឹត្តខ្លួនបានល្អ ក្លាយជាកូនដ៏ល្អ ជាសិស្សដ៏ល្អ ជាមិត្តដ៏ល្អ ជាពលរដ្ឋដ៏ល្អ និងជាពុទ្ធសាសនិកជនដ៏ល្អ មានទស្សនៈវិស័យទូលំទូលាយក្នុងការទទួលខុសត្រូវនូវតួនាទីជាយុវជនខ្មែរ ដែលត្រូវស្នងវង្សត្រកូលប្រទេសជាតិទៅថ្ងៃអនាគត ធ្វើតែប្រយោជន៍សុខដល់ខ្លួនឯង ដល់អ្នកដទៃ ដល់សង្គមប្រទេសជាតិ និងសង្គមលោកទាំងមូល។

<u>➊ អាសយដ្ឋានទំនាក់ទំនង:</u> **វត្តប្រាសាទបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប ។**

☞ ភិក្ខុ **វ៉ាត់ វិបុល** — ប្រធានមជ្ឈមណ្ឌលព្រះពុទ្ធសាសនាអប់រំយុវជន និងជាប្រធានគម្រោង
ទូរស័ព្ទលេខ : (៨៥៥) ១២ ៣១២-៩០៨, ០៩០-៧២២-០៥០
Email: kyso2005@yahoo.com http://www.cambodianyouth.org

☞ ភិក្ខុ មហា **ហ៊ឺ សុន្ធរា** — ប្រធានផ្នែកអប់រំ (គង់នៅវត្តសំពៅមាស រាជធានីភ្នំពេញ)
ទូរស័ព្ទលេខ : (៨៥៥) ១២ ៣២៩ ៦៩៤, (៨៥៥) ២៣៦ ៣៦៣ ៤៩៦

☞ ភិក្ខុ មហា **ដោក ដុំ** — ហិរញ្ញិក (គង់នៅវត្តបទុមវតី កុដិលេខ៣៣ រាជធានីភ្នំពេញ)
ទូរស័ព្ទលេខ : (៨៥៥) ១២ ៩១៣ ៧២៤

☞ លោក **សេង សុវណ្ណ** — ប្រធានទីប្រឹក្សានិងឧបត្ថម្ភកម្មវិធី (ប្រទេសកាណាដា)
ទូរស័ព្ទលេខ : (៤០៣) ៤៥៥ ៨២៩៤

☞ លោក **មូ ពៅ** — ប្រធានទីប្រឹក្សានិងឧបត្ថម្ភកម្មវិធី (រាជធានីភ្នំពេញ)
ទូរស័ព្ទលេខ : (៨៥៥) ១៧ ៣៧៩ ៧៣០

សូមអរព្រះគុណ និងសូមអរគុណ!